**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តភ្នំពេញ**

ថ្ងៃ ពុធ ១១ កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព. ស. ២៥៦៦

លេខ...១៦៤/២២....ក. ស. ភ.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០២២

# សេចក្ដីប្រកាសព័ត៌មាន
# ស្ដីពីលទ្ធផលមហាសន្និបាតភាគហ៊ុនិកលើកទី៧
# របស់កំពង់ផែស្វយ័តភ្នំពេញ

**កំពង់ផែស្វយ័តភ្នំពេញ** (**ក. ស. ភ.**) មានកិត្តិយសសូមគោរពជម្រាបជូនវិនិយោគិន និងសាធារណជនមេត្តាជ្រាបថា នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ៨:០០ នាទីព្រឹក នៅទីស្នាក់ការកណ្ដាលរបស់ ក. ស. ភ. បានរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី៧ ក្រោមអធិបតីភាព **ឯកឧត្ដម តូច ចាន់កុសល** រដ្ឋលេខាធិការប្រចាំការ តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន, **ឯកឧត្ដម កែន សម្បត្តិ** សមាជិកក្រុមប្រឹក្សាភិបាល តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, និង **ឯកឧត្ដម ហ៊ី បាវី** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានអគ្គនាយក និងជាប្រធានមហាសន្និបាត ព្រមទាំងមានការចូលរួមពីភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ភាគហ៊ុនិក និងថ្នាក់ដឹកនាំ ក. ស. ភ. ផងដែរ។ មហាសន្និបាតភាគហ៊ុនិកលើកទី៧ ប្រព្រឹត្តទៅយ៉ាងរលូន ដោយមានភាគហ៊ុនវត្តមានចំនួន ១៩ ២៦១ ៦០៧ ភាគហ៊ុន ស្មើនឹង ៩៣,១% នៃចំនួនភាគហ៊ុនសរុប និងទទួលបានលទ្ធផលដូចខាងក្រោម :

១. បានទទួលជ្រាបអំពីលទ្ធផលអាជីវកម្ម/សេវាកម្ម និងហិរញ្ញវត្ថុ ប្រចាំឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២

២. បានអនុម័តលើការបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២១ ដោយក្នុងនោះ :

- ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិសរុប (Total Dividend per Share) : ២១១,៦០រៀល
  - ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិសម្រាប់ភាគហ៊ុនិកប្រភេទ "ក" : ៣៣២,៨០រៀល
  - ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិសម្រាប់ភាគហ៊ុនិកប្រភេទ "ខ" : ១៨១,៣០រៀល

៣. បានធ្វើការបោះឆ្នោតជ្រើសរើសអភិបាលអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជនសម្រាប់អាណត្តិទី៨ នៃក្រុមប្រឹក្សាភិបាល ក. ស. ភ. ដែលរួមមាន :

- បេក្ខជនជាប់ឆ្នោតជាអភិបាលឯករាជ្យ គឺ **លោក ហ៊្លី អានវ៉ានិថ** ទទួលបាន ១៧ ១៨៣ ១០៦ សម្លេង ស្មើនឹង ៨៩,២% នៃចំនួនភាគហ៊ុនសរុបដែលបានបោះឆ្នោត
- បេក្ខជនជាប់ឆ្នោតជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន គឺ **អ្នកស្រី ប៉ុក ភក្ដី** ទទួលបាន ១ ៩៩៦ ៤៦៣ សម្លេង ស្មើនឹង ៧៣,៦% នៃចំនួនភាគហ៊ុនសរុបដែលបានបោះឆ្នោត។

អង្គមហាសន្និបាតភាគហ៊ុនិកលើកទី៧ បានបញ្ចប់នៅវេលាម៉ោង ១១:៣០ នាទីព្រឹក នៅថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល និងការទទួលខុសត្រូវខ្ពស់។

**កំពង់ផែស្វយ័តភ្នំពេញ**

PHNOM PENH AUTONOMOUS PORT

ទីស្នាក់ការកណ្ដាល: អគារលេខ ៦៤៩ តីវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៨២៧ ៨០២ Email: ppapmpwt@online.com.kh